# ការប្រគល់សិទ្ធិដល់អ្នកជួយ/ភ្នាក់ងារជំនួយការក្រុមហ៊ុនធានារ៉ាប់រង

អ្នកបានជ្រើសរើសយក ____________________ ឲ្យធ្វើការជាអ្នកជំនួយរបស់អ្នក សម្រាប់ការបំពេញព័ត៌មាន និងធ្វើបច្ចុប្បន្នភាពពាក្យសុំ MNsure របស់អ្នក ។ ដោយការចុចលើពាក្យ "Confirm" (បញ្ជាក់) គឺមានន័យថា ឆ្លងតាមរយៈនេះ អ្នកប្រគល់សិទ្ធិឲ្យអ្នកជំនួយរូបនេះ បំពេញការងារតំណាងឲ្យរូបអ្នក និងតំណាងឲ្យអ្នកដទៃដែលមានឈ្មោះនៅក្នុងពាក្យសុំរបស់អ្នក សម្រាប់បំពេញសកម្មភាពដូចតទៅ ៖

- អាចបើកមើលទិន្នន័យរបស់អ្នក ដើម្បីផ្តល់សេវាកម្មបម្រើអតិថិជន
- បញ្ចូលព័ត៌មានអំពីរូបអ្នក និងគ្រួសាររបស់អ្នកទៅក្នុងបែបបទពាក្យសុំ
- ដាក់ស្នើពាក្យសុំសម្រាប់អ្នក
- ជ្រើសរើសផែនការធានារ៉ាប់រងសុខភាពដែលអ្នកមានលក្ខណៈសម្បត្តិអាចទទួលបាន
- ជ្រើសរើស និងដាក់ពាក្យសុំបរិមាណបុព្វលាភឥណទានពន្ធកម្រិតឈានមុខ
- ក្នុងករណីជាឈ្មួញកណ្តាល អាចចូលបើកមើលព័ត៌មានលំអិតក្នុងគណនី ជាមួយនឹងក្រុមហ៊ុនផ្តល់ធានារ៉ាប់រងសុខភាព ដែលអ្នកបានចុះឈ្មោះជាសមាជិក ។

អ្នកក៏អនុញ្ញាតឲ្យអ្នកជំនួយការនេះ អាចផ្តល់ និងពិនិត្យមើលព័ត៌មានចំពោះសមាជិកទាំងអស់ដែលអ្នកបានសរសេរឈ្មោះចូលក្នុងពាក្យសុំនេះ ។ អ្នកដាក់ពាក្យសុំ MNsure ឬអ្នកជំនួយការ ដែលជាអ្នកផ្តល់ និងពិនិត្យមើលព័ត៌មាន ជំនួសមុខឲ្យអ្នកដាក់ពាក្យសុំ ឬសមាជិកគ្រួសារ អ្នកនៅក្នុងបន្ទុកនិយោជិក ឬអ្នកដទៃ បញ្ជាក់ថា ពួកគេទទួលបានការអនុញ្ញាតឲ្យទទួលខុសត្រូវទិន្នន័យបុគ្គល ឬជាអាណាព្យាបាលស្របច្បាប់ ឬបើមិនដូច្នេះទេ គឺបានទទួលសិទ្ធិអាចចូលមើល និងដាក់ស្នើព័ត៌មានទាំងនេះ ហើយត្រូវយល់ព្រមរក្សាព័ត៌មាននេះមិនឲ្យលេចចេញទៅអ្នកទីបី ។ បុគ្គលដែលពិនិត្យមើល ឬដាក់ស្នើព័ត៌មានជំនួសឲ្យអ្នកដទៃ ក៏យល់ព្រមប្រើតែព័ត៌មានអត្តសញ្ញាណបុគ្គលផ្ទាល់ខ្លួន សម្រាប់តែគោលបំណងការបំពេញពាក្យសុំត្រឹមត្រូវ ឬធ្វើទៅតាមអ្វីដែលជាភាពតម្រូវរបស់ច្បាប់រដ្ឋ ឬច្បាប់សហព័ន្ធ និងត្រូវរក្សាទិន្នន័យមិនឲ្យអ្នកដែលមិនបានទទួលសិទ្ធិអាចបើកមើល ប្រើ កែសម្រួល បំផ្លាញ លួច ឬលាតត្រដាងបានឡើយ ។ ព័ត៌មាននៅក្នុងពាក្យសុំរបស់អ្នកគឺជាទិន្នន័យឯកជន ។

ដោយការចុចលើពាក្យ "Confirm" គឺមានន័យថា អ្នកបានអនុញ្ញាតឲ្យអ្នកជំនួយរូបនេះ អាចទទួលបានព័ត៌មានអំពីពាក្យសុំរបស់អ្នក ហើយអាចអនុវត្តសកម្មភាពពាក់ព័ន្ធនឹងពាក្យសុំនេះ បូករួមទាំងការចុះហត្ថលេខាលើពាក្យសុំរបស់អ្នកជំនួសឲ្យរូបអ្នក ហើយចុះឈ្មោះអ្នកជាសមាជិកក្នុងផែនការថែទាំសុខភាពដែលអ្នកមានលក្ខណៈសម្បត្តិអាចទទួលបាន ជំនួសឲ្យរូបអ្នក ។

ដោយការចុចលើពាក្យ "Confirm" គឺមានន័យថា អ្នកបានទទួលស្គាល់ថា អ្នកនៅតែមានការទទួលខុសត្រូវបំពេញឲ្យបានទៅតាមកាលបរិច្ឆេទផុតកំណត់របស់ពាក្យសុំក្នុងការចុះឈ្មោះដើម្បីបានទទួលធានារ៉ាប់រងសុខភាព ។

នៅមុនពេលអ្នកព្រមទទួលយក សូមពិនិត្យមើលឡើងវិញនូវ ការរំឭកពីឯកជនភាពរបស់ MNsure (MNsure Privacy Warnings) ដែលរៀបរាប់អំពីគោលបំណង និងចេតនានៃការប្រើទិន្នន័យឯកជនដែលប្រមូលយកពីពាក្យសុំរបស់អ្នក ហើយថាតើវានឹងមានផលវិបាកចំពោះការបដិសេធមិនផ្តល់ឲ្យដែរឬទេ ។ ការរំឭកអំពីឯកជនភាព ក៏កំណត់អំពីអង្គភាព និងបុគ្គល ដែលយើងខ្ញុំអាចចែករំលែកព័ត៌មានរបស់អ្នកទៅឲ្យ និងរយៈពេលដែល MNsure ត្រូវរក្សាព័ត៌មានរបស់អ្នកទុក ។ សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិឯកជនភាព និងការទទួលខុសត្រូវ គឺមានបង្ហោះនៅឯ ទំព័រលក្ខ័ណ្ឌ និងឯកជនភាព (Terms and Privacy) ។

អ្នកអាចបញ្ចប់ការប្រគល់សិទ្ធិនេះបានគ្រប់ពេលវេលាតាមរយៈគណនី MNsure អនឡាញរបស់អ្នក ឬដោយការហៅទូរស័ព្ទមកកាន់មជ្ឈមណ្ឌលទំនាក់ទំនងរបស់ MNsure (MNsure Contact Center) ។

បើអ្នកមិនមានបំណងផ្តល់សិទ្ធិឲ្យអ្នកជំនួយការរូបនេះអនុវត្តសកម្មភាពទាំងនេះទេ សូមចុចលើពាក្យ "Cancel" (បដិសេធ) ។